ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ...៤៧០...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបំពេញបន្ថែមនាយកដ្ឋានមួយចំនួន
## នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្របក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និង កែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ មានគោលបំណងបំពេញបន្ថែមនាយកដ្ឋានមួយចំនួនទៅតាមខ្លឹមសារ និង រចនាសម្ព័ន្ធ ដែលមានចែងក្នុងអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា២ .-**

ត្រូវបានបំពេញបន្ថែមនាយកដ្ឋានចំនួន ០២ ដូចខាងក្រោម ដែលស្ថិតចំណុះឱ្យក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ :

- នាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍
- នាយកដ្ឋានព័ត៌មានវិទ្យា

## ជំពូកទី ២

## អំពីរចនាសម្ព័ន្ធគ្រប់គ្រង

**មាត្រា៣ .-**

ក-នាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ដឹកនាំ និង គ្រប់គ្រងដោយប្រធាននាយកដ្ឋានមួយរូប និង អនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ ។ នាយកដ្ឋាននេះមានការិយាល័យចំណុះមួយចំនួនតាមតម្រូវការចាំបាច់ ។

ខ-នាយកដ្ឋានព័ត៌មានវិទ្យាដឹកនាំ និង គ្រប់គ្រងដោយប្រធាននាយកដ្ឋានមួយរូប និង អនុប្រធាននាយកដ្ឋានមួយចំនួនជាជំនួយការ ។ នាយកដ្ឋាននេះមានការិយាល័យចំណុះមួយចំនួនតាមតម្រូវការចាំបាច់ ។

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនៃនាយកដ្ឋានទាំងពីរខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

# ជំពូកទី ៣
# អំពីភារកិច្ច

**មាត្រា៤ .-**

នាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍មានតួនាទី និង ភារកិច្ចធ្វើជាសេនាធិការរបស់ក្រសួងលើការងារ :

- គោរពអនុវត្តតាមការណែនាំ ការបញ្ជា ឬសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីលើការដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ចសង្គមដោយសារគម្រោងអភិវឌ្ឍន៍
- រៀបចំក្រុមការងារតាមតម្រូវការចាំបាច់ជាក់ស្តែង ផ្អែកលើសំណើបច្ចេកទេសរបស់ស្ថាប័នអនុវត្តគម្រោង ដើម្បីចុះធ្វើការអង្កេតវាស់វែងលម្អិត វាយតម្លៃអំពីផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ដែលតម្រូវឱ្យមានការធ្វើលទ្ធកម្មដី ទ្រព្យសម្បត្តិផ្សេងៗ សិទ្ធិ និងផលប្រយោជន៍នានាលើដីសម្រាប់បំរើផលប្រយោជន៍សាធារណៈ ឬ ផលប្រយោជន៍ជាតិ
- រៀបចំលិខិតជូនដំណឹងអំពីការដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ចសង្គម ដល់អាជ្ញាធរមានសមត្ថកិច្ច និង ភ្នាក់ងារអនុវត្តគម្រោង
- រៀបចំផែនការស្តីពីការដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ចសង្គម ដោយសារគម្រោងអភិវឌ្ឍន៍ ដោយមានការចូលរួមពីប្រជាពលរដ្ឋ ដែលរងនូវផលប៉ះពាល់ដោយសារគម្រោង
- រៀបចំគម្រោងថវិកាសម្រាប់ការសិក្សាអង្កេតបឋម ឬ ការអង្កេតវាស់វែង លម្អិត ដើម្បីបញ្ចូលទៅក្នុងផែនការស្តីពីការដោះស្រាយផលប៉ះពាល់ ដោយសារគម្រោងអភិវឌ្ឍន៍
- រៀបចំឱ្យមានយន្តការវាយតម្លៃដី ទ្រព្យសម្បត្តិផ្សេងៗ ដែលរងនូវផលប៉ះពាល់ដោយសារគម្រោង ដើម្បីជាមូលដ្ឋានសម្រាប់ទូទាត់សំណងឱ្យបានសមរម្យ និង យុត្តិធម៌ ជូនប្រជាពលរដ្ឋ ដែលរងនូវផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍
- រៀបចំសំណើថវិកាពេញលេញសម្រាប់អនុវត្តផែនការ ស្តីពីការដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ចសង្គមដោយសារគម្រោងអភិវឌ្ឍន៍ ដោយផ្អែកលើលទ្ធផលនៃការអង្កេតវាស់វែងលម្អិតអំពី ផលប៉ះពាល់ និង លទ្ធផលនៃការសិក្សាវាយតម្លៃដី ទ្រព្យសម្បត្តិ ដែលរងនូវផលប៉ះពាល់ដោយសារគម្រោង
- សហការជាមួយនាយកដ្ឋានពាក់ពន្ធ័នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការរៀបចំគម្រោងថវិកាប្រចាំឆ្នាំសម្រាប់ការងារដោះស្រាយផលប៉ះពាល់
- សហការជាមួយនាយកដ្ឋានជំនាញនៃក្រសួង ស្ថាប័នអនុវត្តគម្រោងដទៃទៀត ក្នុងការអនុវត្តផែនការសកម្មភាពស្តីពីការដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍
- ធ្វើការតាមដានផ្ទៃក្នុង លើសកម្មភាពអនុវត្តផែនការស្តីពីការដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ចសង្គមដោយសារគម្រោង

- រៀបចំឱ្យមានការតាមដានត្រួតពិនិត្យដោយភ្នាក់ងារឯករាជ្យ ចំពោះអនុលោមភាពនៃការអនុវត្តផែនការស្តីពីការដោះស្រាយផលប៉ះពាល់
- ចូលរួមជាមួយតំណាងភ្នាក់ងារអនុវត្តគម្រោង និងអាជ្ញាធរដែនដីនៅពេលប្រគល់ទទួលគម្រោងដែលបានសាងសង់ ស្តារ ឬ ជួសជុលរួច ដើម្បីពិនិត្យផ្ទៀងផ្ទាត់លើការប្រើប្រាស់ជាក់ស្តែងនូវដី ឬទ្រព្យសម្បត្តិ ដែលត្រូវបានធ្វើលទ្ធកម្មសម្រាប់បម្រើឱ្យគម្រោង ហើយដែលបានប្រើប្រាស់ថវិកាជាតិ ឬ ថវិកា ដែលបានមកពីហិរញ្ញប្បទានសហប្រតិបត្តិការនានា
- សហការជាមួយនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងនាយកដ្ឋាន ឬអង្គភាពជំនាញនៃក្រសួង ស្ថាប័នអនុវត្តគម្រោង ក្នុងការរៀបចំឱ្យមានការចុះបញ្ជីដីធ្លីក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ចំពោះ ដីធ្លីដែលបានធ្វើលទ្ធកម្មសម្រាប់អនុវត្តគម្រោង និង ប្រគល់ជូនស្ថាប័នអនុវត្តគម្រោង ដើម្បីកាន់កាប់ និង គ្រប់គ្រង
- តំណាងឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅក្នុងករណីដែលមានការប្តឹងតវ៉ាទៅតុលាការទាក់ទងនឹងការដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ចសង្គម ឬ បញ្ហាទូទាត់សងសំណង ឬ លក្ខណៈសម្បត្តិក្នុងការទទួលបាននូវជំនួយឧបត្ថម្ភផ្សេងៗ
- សិក្សា ស្រាវជ្រាវ កសាងលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធនឹងគោលនយោបាយដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ចសង្គមដោយសារគម្រោងអភិវឌ្ឍន៍
- បំពេញការងារផ្សេងទៀត តាមការណែនាំរបស់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា៩ .-**

នាយកដ្ឋានព័ត៌មានវិទ្យាមានតួនាទី និងភារកិច្ចធ្វើជាសេនាធិការរបស់ក្រសួងលើការងារ :

- គោរពអនុវត្តតាមការណែនាំ ការបញ្ជា ឬ សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលើការងារពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យបច្ចេកវិទ្យាព័ត៌មានវិទ្យា និង ទូរគមនាគមន៍
- រៀបចំ បង្កើត និង ពង្រឹងយុទ្ធសាស្ត្រ និង គោលនយោបាយបច្ចេកវិទ្យាព័ត៌មានវិទ្យា និង ទូរគមនាគមន៍ ដើម្បីទ្រទ្រង់ដល់ការកែទម្រង់ការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាព និង តម្លាភាព
- ចងក្រង និង ពិនិត្យលើច្បាប់នានា ដែលអាចជះ ឬ ទទួលឥទ្ធិពលពីការអនុវត្តគម្រោងការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ និង គម្រោងពាក់ព័ន្ធទៅនឹងវិស័យបច្ចេកវិទ្យាព័ត៌មានវិទ្យា និង ទូរគមនាគមន៍នានា
- ពង្រឹងការអនុវត្តច្បាប់កម្មសិទ្ធិបញ្ញា និង ច្បាប់ពាក់ព័ន្ធនឹងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា និង ទូរគមនាគមន៍ និង ប្រព័ន្ធអ៊ីនធឺណេត
- អនុវត្ត និង គ្រប់គ្រងគម្រោង «ការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ» នៅគ្រប់ដំណាក់កាល ដើម្បីធានាឱ្យបាននូវគោលដៅនៃកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង និង រាជរដ្ឋាភិបាល

- ទទួលខុសត្រូវក្នុងកិច្ចលទ្ធកម្មលើបណ្តាញតភ្ជាប់ ម៉ាស៊ីនកុំព្យូទ័រ ឧបករណ៍ព័ត៌មានវិទ្យា និង កម្មវិធីកុំព្យូទ័រចំពោះគម្រោង ដែលផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ ជាពិសេសគម្រោងការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ
- ចូលរួមក្នុងកិច្ចលទ្ធកម្មលើសម្ភារៈបច្ចេកវិទ្យាព័ត៌មានវិទ្យា និង ទូរគមនាគមន៍ ដែលប្រើប្រាស់ថវិកាជាតិ ជាមួយនឹងនាយកដ្ឋានពាក់ព័ន្ធនៅក្នុងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ធ្វើសហប្រតិបត្តិការក្នុងក្របខ័ណ្ឌជាតិ តំបន់ និង អន្តរជាតិលើការងារពាក់ព័ន្ធការអភិវឌ្ឍវិស័យ បច្ចេកវិទ្យាព័ត៌មានវិទ្យា និង ទូរគមនាគមន៍ សម្រាប់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដូចជា ដំណើរការបង្កើត រដ្ឋាភិបាលអេឡិកត្រូនិក កិច្ចលទ្ធកម្មអេឡិកត្រូនិក និង ពាណិជ្ជកម្មអេឡិក-ត្រូនិក ជាដើម
- បង្កើតប្រព័ន្ធសុវត្ថិភាព និង ថែរក្សាឯកសារប្រកបដោយសុវត្ថិភាព សម្រាប់អ្នកប្រើប្រាស់ម៉ាស៊ីនកុំព្យូទ័រនៅក្នុងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ពង្រឹងការអនុវត្ត និង ផ្សព្វផ្សាយស្តីពីការគ្រប់គ្រងការផ្លាស់ប្តូររបស់គម្រោងការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាក្នុងវិស័យហិរញ្ញវត្ថុសាធារណៈដល់មន្ត្រីរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនៅគ្រប់ជាន់ថ្នាក់ និង គ្រប់បណ្តាក្រសួង- ស្ថាប័នទាំងអស់នៃរាជរដ្ឋាភិបាល
- បណ្តុះបណ្តាលការប្រើប្រាស់ការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា ក្នុងវិស័យហិរញ្ញវត្ថុសាធារណៈដល់ក្រសួង- ស្ថាប័ននៃរាជរដ្ឋាភិបាលដោយសហការជាមួយវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង វិទ្យាស្ថានបណ្តុះបណ្តាលដទៃទៀត
- គាំទ្រដល់ការរៀបចំ និង ការអនុវត្តថវិកាជាតិតាមរយៈគម្រោងការគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យាក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ
- ផ្តល់សេវាផ្នែកបច្ចេកវិទ្យាព័ត៌មានវិទ្យា និង ទូរគមនាគមន៍នានា ដូចជា សេវាអ៊ីនធឺណែត អ៊ីមែល គេហទំព័រ ការចែករំលែកឯកសារ ការរៀបចំអង្គសន្និសិទតាមប្រព័ន្ធបច្ចេកវិទ្យា ព័ត៌មានវិទ្យា និង សេវាដទៃទៀតសម្រាប់នាយកដ្ឋានទាំងអស់នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ទទួលខុសត្រូវលើការគ្រប់គ្រង ជួសជុល និង ថែរក្សាបណ្តាញតភ្ជាប់ ម៉ាស៊ីនកុំព្យូទ័រ ឧបករណ៍ព័ត៌មានវិទ្យា និង កម្មវិធីកុំព្យូទ័រនានានៅក្នុងនាយកដ្ឋានទាំងអស់នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បំពេញការងារផ្សេងទៀតក្នុងវិស័យបច្ចេកវិទ្យាព័ត៌មានវិទ្យា និង ទូរគមនាគមន៍ តាមការណែនាំរបស់ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា៦ . -**

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ០៤ អនក្របក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០, ឧបសម្ព័ន្ធនៃអនុក្រឹត្យ

លេខ ០៦ អនក្របក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ និង អនុក្រឹត្យលេខ ៧៨ អនក្របក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីអង្គការលេខរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបានកែសម្រួលដូចឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងអនុក្រឹត្យនេះ ។

**មាត្រា៧ . -**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៨ . -**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

***<u>ចម្លងជូន</u> :***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *គ្រប់ក្រសួងស្ថាប័នកណ្តាល*
- *គ្រប់សាលាខេត្ត ក្រុង និងរាជធានីភ្នំពេញ*
- *គណៈកម្មាការអន្តរក្រសួងដោះស្រាយផលប៉ះពាល់*
- *ដូចមាត្រា ៨*

ឧបសម្ព័ន្ធអនុក្រឹត្យលេខ..............អនក្រ.បក ចុះថ្ងៃទី................ខែ ...............ឆ្នាំ ២០០៨

# អង្គការលេខរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

